ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

លេខ : ✓ មស.

# សាររំលែកទុក្ខ

## ជូនចំពោះ

## លោក ខេន ផល្លី ប្រធានមន្ទីរមុខងារសាធារណៈខេត្តកំពង់ឆ្នាំង និងក្រុមគ្រួសារ

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ មានក្ដីសោកស្ដាយ រំជួលចិត្តក្រៃលែង ដោយបានទទួលដំណឹងថា ឧបាសក នុក យ៉ាន ដែលត្រូវជាឪពុកបង្កើតលោក ខេន ផល្លី ប្រធានមន្ទីរមុខងារសាធារណៈខេត្តកំពង់ឆ្នាំង បានទទួលមរណភាពនៅថ្ងៃអាទិត្យ ៣រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង៤:៥០នាទីទាបភ្លឺ ក្នុងជន្មាយុ៧៥ឆ្នាំ ដោយជរាពាធ។

ក្នុងឱកាសប្រកបដោយក្ដីរំជួលចិត្ត និងសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមចូលរួមសម្ដែងនូវមរណទុក្ខដ៏ក្រៀមក្រំ និងសោកស្ដាយជាអនេកប្បការជាមួយលោក និងក្រុមគ្រួសារ ចំពោះការបាត់បង់ឧបាសក នុក យ៉ាន ដែលត្រូវជាឪពុកបង្កើត និងជីតាដែលជាទីគោរពស្រលាញ់របស់ខ្លួន។

ជាមួយគ្នានេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមឧទ្ទិសបួងសួងជូនដួងវិញ្ញាណក្ខន្ធ ឧបាសក នុក យ៉ាន បានសោយសុខក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម លោក និងក្រុមគ្រួសារ ទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីខ្ញុំ។

ថ្ងៃអាទិត្យ ៣រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២១

**ត.ប.រដ្ឋមន្ត្រី**
**អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ**

**សយ គេន:**

ផ្លូវវិថីអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh